# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

## Inside

**Infographic**
"ASEAN Trade Overview"

**Local & Global News**

**Opinion Article**
"Legal Regime on Personal Data Protection under E-commerce law in Cambodia"
*Mr. KEO Buntheng*

វ៉ុល០២ | លេខ០៣ | ខែកញ្ញា ឆ្នាំ២០២២
VOLUME 02 | ISSUE 03 | SEPTEMBER 2022

ASEAN CAMBODIA 2022
ASEAN A.C.T: Addressing Challenges Together

# អាស៊ាន
# ទិដ្ឋភាពពាណិជ្ជកម្ម

រៀបចំដោយ

សូមស្កេនដើម្បីទាញយក ព្រឹត្តិបត្រពាណិជ្ជកម្ម



## ព័ត៌មានអាស៊ានសំខាន់ៗ & សមាជិកភាព



**សេដ្ឋកិច្ចអាស៊ាន**

**៣,៣ ទ្រីលានដុល្លារ**

ជាសេដ្ឋកិច្ចធំជាងគេទី ៥ នៅលើពិភពលោកក្នុងឆ្នាំ ២០២១

**ពាណិជ្ជកម្មសរុប**




**៣.៤២៧,៧៧** ប៊ីលានដុល្លារអាមេរិក

(ប្រភព៖ ITC, Trade Map)

| ៨ សីហា ១៩៦៧ | ៧ មករា ១៩៨៤ | ២៨ កក្កដា ១៩៩៥ | ២៣ កក្កដា ១៩៩៧ | ៣០ មេសា ១៩៩៩ |
|---|---|---|---|---|
| ឥណ្ឌូនេស៊ី<br>ម៉ាឡេស៊ី<br>ហ្វីលីពីន<br>សិង្ហបុរី<br>ថៃ | ប្រ៊ុយណេ ដារូសាឡឹម | វៀតណាម | ឡាវ<br>មីយ៉ាន់ម៉ា | កម្ពុជា |

## ដៃគូពាណិជ្ជកម្មសំខាន់ៗ




៧៣២,៩៦ ប៊ីលានដុល្លារអាមេរិក (២១,៣៨%)

៣៧៣,៧៨ ប៊ីលានដុល្លារអាមេរិក (១០,៩០%)

២៨២,០១ ប៊ីលានដុល្លារអាមេរិក (៨,២៣%)

២៣៨,៩០ ប៊ីលានដុល្លារអាមេរិក (៦,៩៧%)

១៩១,២៥ ប៊ីលានដុល្លារអាមេរិក (៥,៥៨ %)

(ប្រភព៖ ITC, Trade Map)

## សសរស្តម្ភសហគមន៍អាស៊ាន

- សហគមន៍ នយោបាយ-សន្តិសុខអាស៊ាន
- សហគមន៍ សេដ្ឋកិច្ចអាស៊ាន
- សហគមន៍ វប្បធម៌សង្គមអាស៊ាន

សហគមន៍សេដ្ឋកិច្ចអាស៊ាន:

- ទីផ្សារតែមួយ និង មូលដ្ឋានផលិតកម្ម
- តំបន់សេដ្ឋកិច្ច ប្រកួតប្រជែង
- ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយសមធម៌
- សមាហរណកម្មទៅក្នុង សេដ្ឋកិច្ចសកល

## កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន

អាស៊ាន-សាធារណរដ្ឋកូរ៉េ
បានចុះហត្ថលេខានៅឆ្នាំ ២០០៥

អាស៊ាន-ចិន
បានចុះហត្ថលេខានៅឆ្នាំ ២០០២

អាស៊ាន-អូស្ត្រាលី-នូវែលសេឡង់
បានចុះហត្ថលេខាកាលពីឆ្នាំ២០០៩

អាស៊ាន-ជប៉ុន
បានចុះហត្ថលេខានៅឆ្នាំ ២០០៨

អាស៊ាន-ហុងកុង
បានចុះហត្ថលេខានៅឆ្នាំ ២០១៨

អាស៊ាន-ឥណ្ឌា
បានចុះហត្ថលេខានៅឆ្នាំ ២០០៣

អាស៊ាន-សហភាពអឺរ៉ុប
(ការចរចាត្រូវបានផ្អាកពីឆ្នាំ ២០០៩)

អាស៊ាន-កាណាដា
(ក្នុងការចរចា)

កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់
បានចុះហត្ថលេខានៅឆ្នាំ ២០២០

ASEAN CAMBODIA 2022
ASEAN A.C.T: Addressing Challenges Together

# ASEAN Trade Overview

Organized by

Please scan to download iTrade Bulletin

FIRST EDITION

## PROFILE & MEMBERSHIPS

GDP

**3.3 US$ trillion**

5TH largest economy in the world (2021)

TOTAL TRADE




(Source: ITC, Trade Map)



- **8 August 1967**: Indonesia, Malaysia, Philippines, Singapore, Thailand
- **7 January1984**: Brunei
- **28 July 1995**: Viet Nam
- **23 July 1997**: Lao PDR, Myanmar
- **30 April 1999**: Cambodia

## TOP TRADE PARTNERS




- China: 732.96 US$ billion (21.38%)
- United States: 373.78 US$ billion (10.90%)
- European Union (EU-27): 282.01 US$ billion (8.23%)
- Japan: 238.90 US$ billion (6.97%)
- South Korea: 191.25 US$ billion (5.58%)
- Others (46.94%)

(Source: ITC, Trade Map)

## ASEAN COMMUNITY PILLARS

- POLITICAL SECURITY
- ECONOMIC
- SOCIO-CULTURAL

ECONOMIC:

- SINGLE MARKET & PRODUCTION BASE
- COMPETITIVE ECONOMIC REGION
- EQUITABLE ECONOMIC DEVELOPMENT
- INTEGRATION INTO GLOBAL ECONOMY

## ASEAN FTAs

FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC COOPERATION BETWEEN ASEAN AND KOREA
Signed in 2005

FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC CO-OPERATION BETWEEN ASEAN AND CHINA
Signed in 2002

ASEAN-AUSTRALIA-NEW ZEALAND FREE TRADE AGREEMENT (AANZFTA)
Signed in 2009

ASEAN-JAPAN COMPREHENSIVE ECONOMIC PARTNERSHIP AGREEMENT
Signed in 2003

ASEAN - HONG KONG, CHINA FREE TRADE AGREEMENT
Signed in 2018

FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC COOPERATION BETWEEN ASEAN AND INDIA
Signed in 2003

ASEAN-EU
(negotiations suspended since 2009)

ASEAN-CANADA
(in negotiation)

REGIONAL COMPREHENSIVE ECONOMIC PARTNERSHIP (RCEP)
Signed in 2020

## សម្តេចនាយករដ្ឋមន្ត្រី គាំទ្រ ACFTA ជំនាន់ ៣.០

ប្រភព៖ The Phnom Penh Post

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្តែងការគាំទ្រចំពោះការដំឡើងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ឬហៅថា "ជំនាន់ ៣.០" ដែលជំរុញដោយកិច្ចព្រមព្រៀងអាសិប (RCEP) និងបន្ទាប់ពី "ការអនុវត្តដោយជោគជ័យ" នៃកិច្ចព្រមព្រៀង ACFTA ជំនាន់ ១.០ និង ២.០។ សម្តេចនាយករដ្ឋមន្ត្រី ក៏បានអំពាវនាវដល់ប្រទេសចំនួន១១ នៃកិច្ចព្រមព្រៀងនេះ ឱ្យពង្រីកវិសាលភាព និងភាពស៊ីជម្រៅនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយឧបសគ្គចំពោះពាណិជ្ជកម្មទំនិញ សេវាកម្ម និងការវិនិយោគ ព្រមទាំងជំរុញសេដ្ឋកិច្ចឌីជីថល និងការអភិវឌ្ឍបៃតង ក៏ដូចជាការកសាងសមត្ថភាពសម្រាប់សហគ្រាសធុនតូចនិងមធ្យម (SME)។ សម្តេចបានមានប្រសាសន៍ថា កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-ចិនបានសម្រេច "សមិទ្ធិផលផ្លែផ្កាជាច្រើន" ចាប់តាំងពីភាគីទាំងពីរបានចុះហត្ថលេខាលើ "កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងចិន" ក្នុងឆ្នាំ២០០២ និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងវិនិយោគជាបន្តបន្ទាប់។ **ចុចទីនេះដើម្បីអានបន្ថែម**

## សម្តេចនាយករដ្ឋមន្ត្រី ថ្លែងពីយុទ្ធសាស្ត្រ ពេលបើកកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន AEM

ប្រភព៖ The Phnom Penh Post

នៅថ្ងៃទី១៤ខែកញ្ញា ឆ្នាំ២០២២ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរំលឹកសារជាថ្មីអំពីសារសំខាន់នៃ "ការជំរុញយុទ្ធសាស្ត្រសំខាន់ៗចំនួនបួន" ក្រោមក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដើម្បីពន្លឿនការស្តារឡើងវិញ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់នៅក្នុងតំបន់ ស្របពេលមានបញ្ហាជាច្រើនប្រសព្វគ្នាបណ្តាលមកពីការរំខានដោយសារជំងឺកូវីដ-១៩ ក៏ដូចជាការកើនឡើងថ្លៃប្រេង និងអតិផរណា កើតចេញពីសង្គ្រាមនៅអ៊ុយក្រែន។ យុទ្ធសាស្ត្រសំខាន់ៗចំនួនបួន ដែលគាំទ្រដោយសមិទ្ធផលសេដ្ឋកិច្ចអាទិភាពទាំង១៩ របស់កម្ពុជា (PED) សម្រាប់ឆ្នាំ២០២២ មាន៖ ១. ការពង្រឹងការតភ្ជាប់ឌីជីថល វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២. ការកាត់បន្ថយគម្លាតអភិវឌ្ឍន៍សម្រាប់ភាពប្រកួតប្រជែងរបស់អាស៊ាន ៣. ការជំរុញសមាហរណកម្ម បរិយាប័ន្ន ភាពធន់ និងភាពប្រកួតប្រជែងអាស៊ានឱ្យខ្លាំងជាងមុន និង ៤. អាស៊ានជាសកលសម្រាប់កំណើន និងការអភិវឌ្ឍ"។ **ចុចទីនេះដើម្បីអានបន្ថែម**

## រដ្ឋមន្ត្រីយល់ស្របចំពោះការបង្កើតលេខាធិការដ្ឋាន RCEP

ប្រភព៖ Khmer Times

ប្រទេសសមាជិកអាស៊ាន រួមជាមួយអូស្ត្រាលី ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ និងនូវែលសេឡង់ បាន បញ្ចប់កិច្ចប្រជុំរដ្ឋមន្ត្រីអាសិប ដែលប្រព្រឹត្តទៅ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ នៅក្នុងខេត្តសៀមរាប ។ កិច្ចប្រជុំនេះ បានស្វាគមន៍ចំពោះការចូលជាធរមាននៃកិច្ចព្រមព្រៀងអាសិប កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ដែលជូនគ្នានឹងការចាប់ផ្តើមការចរចាកិច្ចព្រមព្រៀងអាសិប កាលពីឆ្នាំ២០១២ ដែលកាលនោះកម្ពុជាក៏ជាប្រធានអាស៊ានផងដែរ។ កិច្ចប្រជុំនេះ បានកត់សម្គាល់នូវវឌ្ឍនភាពនៃការងាររបស់គណៈកម្មាធិការរួមអាសិប និងបានស្វាគមន៍ការបង្កើតនូវអង្គភាពចំណុះក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការរួមនេះ។ កិច្ចប្រជុំក៏បានយល់ស្របចំពោះការពន្លឿន ការបង្កើតលេខាធិការដ្ឋានអាសិប ដើម្បីជួយផ្តល់ការគាំទ្រជាបច្ចេកទេស និងលេខាធិការដល់គណៈកម្មាធិការរួមអាសិប និងអង្គភាពចំណុះ។ **ចុចទីនេះដើម្បីអានបន្ថែម**

## តើអាសិបនឹងជួយដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចអាស៊ានដែរឬទេ ?

ប្រភព៖ Khmer Times

សោកនាដកម្មសេដ្ឋកិច្ចជាបន្តបន្ទាប់រួមមាន ការឆ្លងរាលដាលជំងឺកូវីដ-១៩ សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ការកើនឡើងអតិផរណា ការកើនឡើងតម្លៃលុយដុល្លារ ការតម្លើងអត្រាការប្រាក់ខ្ពស់ ចលាចលទីផ្សារភាគហ៊ុន ការរំខានខ្សែចង្វាក់ផ្គត់ផ្គង់ អថិរភាពថ្លៃថាមពល និងបញ្ហាភូមិសាស្ត្រនយោបាយជាច្រើនទៀត បានបង្ខំឱ្យប្រទេសនានាដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗដើម្បីរស់រាន និងស្តារចេញពីវិបត្តិ។ ក្នុងនោះកិច្ចព្រមព្រៀងអាសិបបានបង្កើតប្រព័ន្ធទីផ្សាររួមមួយដោយលុបបំបាត់របាំងពាណិជ្ជកម្ម ទាំងពន្ធគយ និងមិនមែនពន្ធគយ ព្រមទាំងជានាការទទួលបានច្រកទីផ្សារប្រសើរឡើងសម្រាប់ទំនិញ និងសេវាកម្មរបស់អាជីវកម្ម។ កិច្ចព្រមព្រៀងនេះ ផ្តល់សក្តានុពលដ៏ធំសម្រាប់ប្រទេសចូលរួមទាំងអស់ ជាពិសេសប្រទេសអភិវឌ្ឍន៍តិចតួច ដែលជារដ្ឋសមាជិកអាស៊ាន ក្នុងការជំរុញទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគ និងពន្លឿនការស្តារសេដ្ឋកិច្ចឡើងវិញពីវិបត្តិជំងឺរាតត្បាត។ **ចុចទីនេះដើម្បីអានបន្ថែម**

## សក្តានុពលនៃកិច្ចសហប្រតិបត្តិការត្រីភាគីជប៉ុន-កូរ៉េខាងត្បូង-អាម៉េរិក តាមរយៈ IPEF

ប្រភព៖ The Diplomat

កាលដើមឆ្នាំ២០២២ លោកចូ បៃឌិន បានដាក់ចេញ "ក្របខ័ណ្ឌសេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិក" (IPEF) ដែលជាយុទ្ធសាស្ត្រថ្មីមួយក្នុងការតភ្ជាប់សេដ្ឋកិច្ចអន្តរប៉ាស៊ីហ្វិក ដែលក្របខ័ណ្ឌនេះ មានលើសពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបែបប្រពៃណីផ្សេងទៀត ដែលអាម៉េរិកអាចបំពេញចន្លោះប្រហោងបន្សល់ទុកក្រោយការចាកចេញរបស់ខ្លួនពីកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) ។ ក្របខ័ណ្ឌនេះក៏ជាវេទិកាដ៏មានសក្តានុពលមួយ សម្រាប់ការពង្រឹងកិច្ចសហប្រតិបត្តិការត្រីភាគីរវាងអាម៉េរិក កូរ៉េខាងត្បូង និងជប៉ុនផងដែរ។ ដោយរំពឹងថាក្របខ័ណ្ឌ IPEF នេះនឹងអាចគ្រប់គ្រងការរំខាននានាជាមួយដៃគូពាណិជ្ជកម្ម និងអ្នកផ្គត់ផ្គង់ជាច្រើន កូរ៉េខាងត្បូងបានព្យាយាមបង្កើតកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅជាមួយអាម៉េរិក ដើម្បីឈានទៅបង្កើត "សម្ព័ន្ធភាពចង្វាក់ផ្គត់ផ្គង់" ដែលអាចស្តារឡើងវិញនូវសមត្ថភាពជានាបាននូវសម្ភារយុទ្ធសាស្ត្រ និងសម្របសម្រួលកិច្ចសន្ទនាពហុភាគី។ ជប៉ុន និងអាម៉េរិកប្រឈមមុខនឹងអសន្តិសុខខ្សែចង្វាក់ផ្គត់ផ្គង់ ដោយសារប្រទេសទាំងពីរ ពឹងផ្អែកខ្លាំងលើការនាំចូលទំនិញសំខាន់ៗ។ តាមរយៈ IPEF ដែលជាក្របខ័ណ្ឌពហុភាគី និងមានភាពបត់បែនខ្ពស់ ការចរចាអាចនឹងបន្តទៅមុខដោយមិនមានការរាំងស្ទះឡើយ។ **ចុចទីនេះដើម្បីអានបន្ថែម**

## ការផ្គត់ផ្គង់ប្រេងក្លាយជាក្តីកង្វល់ ស្របពេលដែលថ្លៃប្រេងឡើងខ្ពស់ ខណៈលុយដុល្លារធ្លាក់ថ្លៃ

ប្រភព៖ Reuters

ថ្លៃប្រេងឡើងខ្ពស់ ខណៈប្រាក់ដុល្លារធ្លាក់ថ្លៃ និងក្តីបារម្ភអំពីការផ្គត់ផ្គង់ប្រេង មុនពេលដែលសហភាពអឺរ៉ុបនឹងដាក់ទណ្ឌកម្មលើប្រេងរបស់រុស្ស៊ីនៅចុងឆ្នាំ២០២២នេះ បានបង្កជាក្តីកង្វល់ពីវិបត្តិសេដ្ឋកិច្ចសកល ដែលអាចនាំឱ្យតម្រូវការប្រេងធ្លាក់ចុះ។ តម្លៃប្រេងឆៅរបស់ក្រុមហ៊ុន Brent បានកើនឡើង ៦០ សេន ឬប្រមាណ ០,៧%បន្ថែមទៀត ពោលគឺមានតម្លៃ ៩១,៩៥ ដុល្លារក្នុងមួយបារ៉ែល ឯប្រេងឆៅរបស់ក្រុមហ៊ុន West Texas Intermediate មានតម្លៃ ៨៥,៥០ ដុល្លារ ក្នុងមួយបារ៉ែល កើនឡើង ៣៩ សេន ឬប្រមាណ ០,៥% បន្ថែមទៀត។ កត្តាជាច្រើនដែលរំខានដល់ការផ្គត់ផ្គង់នៅតែជាហានិភ័យ ខណៈដែលគោលនយោបាយបន្ធូរបន្ថយការរឹតត្បិតកូវីដ-១៩ក្នុងប្រទេសចិន ផ្តល់នូវភាពសុទិដ្ឋិនិយមផងដែរ។ ការនាំចេញប្រេងសាំងនិងម៉ាស៊ូតរបស់ចិនក៏មានសន្ទុះឡើងវិញបន្ទាប់ពីទីក្រុងប៉េកាំង បានដាក់ចេញកូតានាំចេញថ្មី។ ក្នុងគោលបំណងផ្គត់ផ្គង់ប្រេងបានកាន់តែច្រើនជាងនេះ ក្រុមហ៊ុនថាមពលរបស់អាម៉េរិកបានបន្ថែមអណ្តូងប្រេង និងឧស្ម័នធម្មជាតិជាលើកដំបូងកាលពីសប្តាហ៍មុន។ **ចុចទីនេះដើម្បីអានបន្ថែម**

## ប្រទេសចិនបានរួមចំណែកជាង ៣០% ដល់កំណើនសេដ្ឋកិច្ចសកល នៅចន្លោះឆ្នាំ២០១៣-២០២១

ប្រភព៖ Reuters

យោងតាមរបាយការណ៍ចេញផ្សាយដោយការិយាល័យស្ថិតិជាតិរបស់ប្រទេសចិនតែក្នុងឆ្នាំ២០២១ សេដ្ឋកិច្ចទាំងមូលរបស់ចិនបានចូលរួមចំណែកប្រមាណ ១៨,៥% នៃទំហំសេដ្ឋកិច្ច សរុបរបស់ពិភពលោក ដែលធ្វើឱ្យចិនក្លាយជាសេដ្ឋកិច្ចធំបំផុតទីពីរនៅក្នុងពិភពលោក និងកើនឡើងប្រមាណ ៧,២% ធៀបនឹងឆ្នាំ២០១២។ ផលិតផលក្នុងស្រុកសរុបរបស់ចិនបានកើនឡើងក្នុងអត្រាកំណើនប្រចាំឆ្នាំជាមធ្យមប្រមាណ ៦,៦% ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២១ ដែលអត្រានេះ កើនលឿនជាងអត្រាកំណើនសេដ្ឋកិច្ចពិភពលោកដែលមានត្រឹម ២,៦% និងខ្ពស់ជាងកំណើនសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានអត្រាកំណើនត្រឹម ៣,៧%។ របាយការណ៍នេះក៏បង្ហាញផងដែរនូវទំហំពាណិជ្ជកម្មទំនិញ និងសេវារបស់ចិន ដែលមានតម្លៃសរុប ៦,៩ ទ្រីលានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២១ ដែលធ្វើឱ្យចិនបន្តជាប់ចំណាត់ថ្នាក់កំពូលលើពិភពលោក។ របាយការណ៍បានបន្ថែមថា ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០ ចិនបានជួយជីវភាព

ប្រជាជនតាមជនបទ ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រចំនួន ៩៨,៩៩ លាននាក់ ចេញពីភាពក្រីក្រ។ **ចុចទីនេះដើម្បីអានបន្ថែម**

## តើលោកខាងលិចអាចកាត់បន្ថយការពឹងផ្អែកលើធនធានកម្របស់ចិនបានដែរឬទេ?

ប្រភព៖ The Diplomat

អាម៉េរិកកំពុងផ្តោតអារម្មណ៍ទៅលើបញ្ហា ថាតើខ្លួនអាចកាត់បន្ថយការពឹងផ្អែកខ្សែចង្វាក់ផ្គត់ផ្គង់លើប្រទេសចិនបានដោយរបៀបណា។ ក្រៅពីសង្គ្រាមពាណិជ្ជកម្មដែលកំពុងបន្តរវាងប្រទេសទាំងពីរ អាម៉េរិកបានដាក់គោលដៅទប់ស្កាត់កំណើនបច្ចេកវិទ្យារបស់ចិនជាយូរមកហើយ ដោយសារតែការព្រួយបារម្ភ ពីលទ្ធភាពដែលចិននឹងប្រើប្រាស់បណ្តាញ 5G ជាអាវុធសម័យថ្មី។ ដោយខ្លាចនិន្នាការនេះអាចរីករាលដាលដល់វិស័យផ្សេងទៀត អាម៉េរិកបានពង្រឹកវិធានការរឹតត្បិតរបស់ខ្លួន ទៅលើអាជីវកម្មរបស់ចិន (ដូចជា ការបន្ថែមក្រុមហ៊ុនថ្មីរបស់ចិនទៅក្នុងបញ្ជីក្រុមហ៊ុនដែលត្រូវបានហាមឃាត់) និងបានប្រកាសដាក់វិធានការដែលកាត់បន្ថយភាពងាយរងគ្រោះរបស់រដ្ឋអាម៉េរិក ចំពោះការកាត់ផ្តាច់ការនាំចូលរបស់ចិន ជាពិសេសលើធនធានកម្រ (REEs)។ បច្ចុប្បន្ននេះ ប្រទេសចិនគ្រប់គ្រងប្រហែល ៨០% នៃផលិតកម្មធនធានកម្រផែនដី។ **ចុចទីនេះដើម្បីអានបន្ថែម**

## បញ្ហាពាណិជ្ជកម្ម៖ តើយើងនៅតែត្រូវការអង្គការ WTO ដែរឬទេ?

ប្រភព៖ The Diplomat

អង្គការពាណិជ្ជកម្មពិភពលោក (WTO) មិនអាចដំណើរការមុខងាររបស់ខ្លួនពេលលេញឡើយ។ អង្គការដែលបានចាប់ផ្តើមជាមួយនឹងគោលបំណងលើកកម្ពស់ពាណិជ្ជកម្មសេរីនេះ បាននិងកំពុងជួបឧបសគ្គដ៏ធំបំផុត ពិសេសគឺប្រព័ន្ធដោះស្រាយវិវាទដែលបែកបាក់ យន្តការចរចាគ្មានប្រសិទ្ធភាព និងគោលនយោបាយមិនច្បាស់លាស់ ដែលធ្វើឱ្យប្រទេសសមាជិកមួយចំនួនកេងប្រវ័ញ្ចយកផលប្រយោជន៍ផ្ទាល់ខ្លួន ពីគ្រប់វិស័យក្រោមអង្គការនេះ និងធ្វើឱ្យអង្គការនេះពោរពេញដោយភាពតានតឹង ព្រមទាំងកាត់បន្ថយទំនុកចិត្តរបស់ប្រទេសសមាជិក លើប្រព័ន្ធអន្តរជាតិ ដែលអង្គការនេះតែងផ្តល់ឱ្យកន្លងមក។ សង្គ្រាមពាណិជ្ជកម្មបានជំរុញរដ្ឋនានា គេចមិនប្រើប្រាស់យន្តការដោះស្រាយជម្លោះដែលមានស្រាប់នៅក្រោមអង្គការនេះ ដែលធ្វើឱ្យធម្មនុញ្ញរបស់អង្គការនេះកំពុងធ្លាក់ចុះកាន់តែខ្លាំង។ ស្របពេលដែលបញ្ហាពាណិជ្ជកម្មនៅតែបន្តកើតមាន ប្រទេសដែលមានអនុត្តរភាពនឹងបន្តទាញយកឧត្តមភាពប្រៀបធៀប និងការប្រកួតប្រជែងរបស់ពួកគេនៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម ដោយដាក់សម្ពាធបន្ថែមទៀតទៅក្នុងប្រព័ន្ធសេដ្ឋកិច្ចពិភពលោក ដែលជាលទ្ធផលនឹងបង្កើនភាពតានតឹងផ្នែកសន្តិសុខ។ **ចុចទីនេះដើម្បីអានបន្ថែម**

## ចិនថា ការផ្តល់ឧបត្ថម្ភធន EV របស់អាម៉េរិក "សង្ស័យថាបានបំពានច្បាប់អង្គការ WTO"

ប្រភព៖ Xinhua

ក្រសួងពាណិជ្ជកម្មចិន បាននិយាយថា ការផ្តល់ឧបត្ថម្ភធនលើរថយន្តអគ្គិសនី (EV) នៅក្នុងច្បាប់ស្តីពីការកាត់បន្ថយអតិផរណារបស់អាម៉េរិក គឺជាការរើសអើង និងសង្ស័យថា បានរំលោភលើច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក។ អ្នកនាំពាក្យក្រសួងពាណិជ្ជកម្មចិន បានប្រាប់សន្និសីទសារព័ត៌មានថា បទប្បញ្ញត្តិដែលពាក់ព័ន្ធការផ្តល់ឥណទានពន្ធសម្រាប់រថយន្ត EV លើលក្ខខណ្ឌនៃការដំឡើង (បង្គុំ) ចុងក្រោយនៅអាម៉េរិកខាងជើង បង្កជាការរើសអើងប្រឆាំងនឹងផលិតផលនាំចូលស្រដៀងគ្នាផ្សេងទៀត ហើយត្រូវបានគេសង្ស័យថា បានរំលោភលើគោលការណ៍ MFN និងប្រព្រឹត្តកម្មជាតិ (NT) ក្រោមអង្គការ WTO។ អ្នកនាំពាក្យនោះបានបន្ថែមទៀតថា ក្នុងនាមជាសមាជិកអង្គការ WTO អាម៉េរិកគួរតែអនុវត្តគោលនយោបាយវិនិយោគនានាដែលមានអនុលោមភាពជាមួយនឹងវិធានរបស់អង្គការ WTO ព្រមទាំងការពារសណ្តាប់ធ្នាប់ពាណិជ្ជកម្មអន្តរជាតិ ដែលគាំទ្រការប្រកួតប្រជែងដោយយុត្តិធម៌។ **ចុចទីនេះដើម្បីអានបន្ថែម**

## PM Backs ACFTA Version 3.0

Source: The Phnom Penh Post

Prime Minister Hun Sen has voiced support for an upgrade of the ASEAN-China Free Trade Area (ACFTA) to what has been termed "Version 3.0", an incarnation he suggested be underpinned by the world's largest trade pact – the Regional Comprehensive Economic Partnership (RCEP), following the "successful implementation" of versions 1.0 and 2.0. He also called on the 11 ACFTA countries to expand and deepen the scope of their economic cooperation, minimize barriers to trade in goods, services and investment, and promote digital-economy and green-growth development as well as capacity building for small- and medium-sized enterprises (SME). He said that ASEAN-China economic cooperation has accomplished "many fruitful achievements" since the two sides signed the "Framework Agreement on Comprehensive Economic Cooperation between ASEAN and China" in 2002 and subsequent linked trade and investment deals. **Click here to read more**

## PM Talks Strategy as AEM Kicks off

Source: The Phnom Penh Post

Prime Minister Hun Sen on September 14 reiterated the importance of the "four key strategic thrusts" under the ASEAN Economic Community (AEC) framework to accelerate recovery in the bloc and promote sustainable, inclusive and resilient economic growth in the region, amid a confluence of shocks stemming from prolonged Covid-19-related disruptions, as well as rising oil prices and inflation tied to the Ukraine conflict. Anchored by Cambodia's 19 priority economic deliverables (PED) for 2022, the four key strategic thrusts are: "Enhancing Digital Connectivity, Science and Technology", "Narrowing the Development Gap for ASEAN's Competitiveness", "Promoting a More Integrated, Inclusive, Resilient and Competitive ASEAN" and "Strengthening Global ASEAN for Growth and Development". **Click here to read more**

## Ministers Agree on Establishment of RCEP Secretariat

Source: Khmer Times

ASEAN Member States alongside Australia, China, Japan, Korea, and New Zealand concluded the inaugural RCEP Ministers' Meeting on 18 September 2022 in Siem Reap province. The meeting welcomed the entry into force of the Regional Comprehensive Economic Partnership (RCEP) Agreement on 01 January 2022, which also almost coincides with the launch of the RCEP negotiations in 2012 when Cambodia was also the ASEAN Chair. The meeting noted the progress of the work of the RCEP Joint Committee and welcomed the establishment of subsidiary bodies under the Joint Committee's supervision. The ministers have also agreed to the expeditious establishment of the RCEP Secretariat to provide secretariat and technical support to the RCEP Joint Committee and its subsidiary bodies. **Click here to read more**

## RCEP Game Changer in ASEAN Economic Recovery?

Source: Khmer Times

A series of economic woes, including the Covid-19 pandemic, the Russia-Ukraine war, inflation, strengthening dollar, hawkish Fed stance, equity markets' mayhem, supply chain disruptions, fluctuating energy prices and several other geopolitical issues have been forcing various countries to adopt new strategies for survival and recovery. Alongside those strategies, RCEP has created a common market system by eliminating many customs limitations, lifting many import and export trade barriers, and securing improved market access for goods and services for businesses. It holds huge potential for all participating countries, especially LDC ASEAN member states, to boost their trade and investment ties and to quicken their economic recovery from the pandemic. **Click here to read more**

### The Potential for Japan-South Korea-US Trilateral Cooperation through IPEF

Source: Diplomat

Earlier this year, U.S. President Joe Biden introduced the Indo-Pacific Economy Framework (IPEF) as a new approach to connecting transpacific economies and that goes beyond traditional free trade agreements to fill the gap left by the U.S. exit from the Trans-Pacific Partnership (TPP). It could also serve as a potential platform for strengthening trilateral cooperation between the United States, South Korea, and Japan. Pinning its hopes on IPEF to manage disruptions through a wider range of trading partners and suppliers, South Korea sees deeper cooperation with the United States as a way to construct "supply chain alliances" that can rebuild capacity, secure strategic materials, and facilitate multilateral dialogue. Tokyo and Washington face supply chain insecurity given their high dependence on the import of critical goods. Through IPEF's multilateral and flexible framework, negotiations may continue without running into roadblocks. **Click here to read more**

### Oil Prices Climb on Weak Dollar, Supply Concerns

Source: Reuters

Oil prices climbed as a weaker dollar and supply concerns ahead of the European Union embargo on Russian oil offset fears of a global recession that could dampen fuel demand. Brent crude futures rose 60 cents, or 0.7%, to $91.95 a barrel after settling up 0.5% while West Texas Intermediate crude was at $85.50 a barrel, up 39 cents, or 0.5%. More supply disruptions remain a risk, while easing Covid-19 restrictions in China could also provide some optimism. China's gasoline and diesel exports also rebounded after Beijing issued fresh quotas. Signalling more supplies from the United States, U.S. energy firms added oil and natural gas rigs for the first time last week. **Click here to read more**

### China Contributes over 30% to World Economic Growth in 2013-2021

Source: Xinhua

In 2021 alone, China's economic aggregate accounted for 18.5 percent of the world's total after currency translation based on average annual exchange rates, the second largest in the world and up 7.2 percentage points from 2012, according to the report released by the National Bureau of Statistics. China's gross domestic product (GDP) expanded at an average annual growth rate of 6.6 percent from 2013 to 2021, higher than the growth pace of 2.6 percent for the global economy and 3.7 percent for developing economies. The report also showed that the total value of China's goods and services trade reached 6.9 trillion U.S. dollars in 2021, continuing to rank top globally. From 2013 to 2020, China had lifted 98.99 million rural residents living below the current poverty line out of poverty, it added. **Click here to read more**

### Can the West Shake Its Dependence on China's Rare Earths?

Source: The Diplomat

The focus of Washington seems to be increasingly on whether, and how, it can decrease its supply-chain dependency on China. Besides the ongoing trade war between the two, the United States has long targeted Chinese technology due to its worries over potential weaponization of 5G networks. In a sign this sentiment is now spreading into other sectors, the Biden administration has recently expanded its restrictive measures on Chinese businesses (such as adding new firms to the Entity List) and announced measures that suggest a growing push to decrease U.S. vulnerability to Chinese import disruptions – particularly on rare earth elements (REEs). As of today, China controls around 80 percent of the production of rare earths. **Click here to read more**

### Trade Troubles: Do We Still Need the WTO?

Source: The Diplomat

The World Trade Organization (WTO) is functionally impotent. An organization that began with the objective of promoting free trade is ironically the biggest obstacle to achieving its own objective today. Between broken dispute settlement systems, ineffective negotiation mechanisms, and ambiguous policies leading to gross self-interested exploitation, the WTO injects more tension than trust in the international system. Trade wars lead states to circumvent existing WTO processes which only further erodes the organization's waning legitimacy. As trade troubles persist, powerful countries will continue exploiting their comparative and competitive

advantages in trade relations, injecting further pressure into the world economic system and increasing security tensions as a result. **Click here to read more**

### China Says U.S. EV Subsidy Provisions "Suspected of Violating WTO Rules"

Source: Xinhua

The electric vehicle (EV) subsidy provisions in the U.S. Inflation Reduction Act are discriminatory and suspected of violating the World Trade Organization (WTO) rules, the Chinese Ministry of Commerce (MOFCOM) said. The relevant provisions, granting tax credits for EVs on the condition of final assembly in North America, discriminate against other similar imported products and are suspected of violating the WTO principles of the most-favored-nation treatment and national treatment, MOC spokesperson Shu Jueting told a press conference. As a WTO member, the United States should implement relevant investment policies in a manner consistent with the WTO rules and safeguard a trade order that upholds fair competition, Shu said. **Click here to read more**

# របបគតិយុត្តស្តីពីការការពារទិន្នន័យបុគ្គលក្រោមច្បាប់ពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា

*ដោយ៖ **លោក កែវ ប៊ុនថេង** ប្រធានការិយាល័យច្បាប់ពាណិជ្ជកម្ម*
*នាយកដ្ឋាននីតិកម្ម នៃក្រសួងពាណិជ្ជកម្ម*

## I. សេចក្តីផ្តើម

កំណើននៃអ្នកប្រើប្រាស់អ៊ីនធឺណិត និងបណ្តាញទំនាក់ទំនងសង្គម បានជំរុញឱ្យសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជាមានសន្ទុះរីកចម្រើនជាខ្លាំង។ ការរីកវិវឌ្ឍយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធឺណិតបានផ្លាស់ប្តូរបន្តិចម្តងៗពីរបៀបដែលប្រជាជនទិញទំនិញនិងសេវាកម្ម។ ការសាយភាយនៃប្រតិបត្តិការអេឡិចត្រូនិក ផ្តល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់ ព្រមទាំងផ្តល់នូវបរិយាកាសអាជីវកម្មដែលមានភាពងាយស្រួល ផាសុកភាព ប្រសិទ្ធភាព ភាពបត់បែន និងការកាត់បន្ថយចំណាយមិនចាំបាច់នានា។ ទោះជាយ៉ាងណាក៏ដោយ ប្រតិបត្តិការអេឡិចត្រូនិកក៏នាំមកនូវបញ្ហាប្រឈម ហានិភ័យ និងភាពមិនច្បាស់លាស់ផ្សេងៗដែលបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់។

“សិទ្ធិឯកជនភាព” និងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យផ្ទាល់ខ្លួន ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗ នៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា៤០ នៃរដ្ឋធម្មនុញ្ញចែងថា “ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារ ទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទត្រូវបានធានា”។ យោងតាមមាត្រានេះ រដ្ឋធម្មនុញ្ញបានទទួលស្គាល់នូវសិទ្ធិឯកជនភាព និងការរក្សាការសម្ងាត់នៃទំនាក់ទំនង ប៉ុន្តែវានៅតែគ្មានភាពច្បាស់លាស់ ថាតើកិច្ចការពារសិទ្ធិឯកជនភាពនៅក្រោមមាត្រានេះនឹងអាចឈានទៅការការពារទិន្នន័យផ្ទាល់ខ្លួនដែរឬទេ។

បច្ចុប្បន្ន ការអភិវឌ្ឍចុងក្រោយនៅក្នុងក្របខ័ណ្ឌច្បាប់នៃកិច្ចការពារទិន្នន័យផ្ទាល់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺអនុលោមទៅតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលកំណត់នូវបទប្បញ្ញត្តិសម្រាប់ការពារទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក។ កិច្ចការពារព័ត៌មានទាំងនោះរួមមាន ការពារការបាត់បង់ ការចូលទៅប្រើប្រាស់ ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការបង្ហាញ ត្រូវបានពិភាក្សាយ៉ាងសង្ខេបនៅក្នុងមាត្រា៣២ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រួមជាមួយនឹងការហាមឃាត់ប្រឆាំងនឹងការជ្រៀតជ្រែកជាមួយប្រព័ន្ធអេឡិចត្រូនិក ការចូលប្រើ ការទាញយក ការបែកធ្លាយព័ត៌មាន ការលុប ឬការផ្លាស់ប្តូរទិន្នន័យដែលបុគ្គលណាម្នាក់បានរក្សាទុកក្នុងបំណងអាក្រក់មានភាពទុច្ចរិត ឬដោយគ្មានការអនុញ្ញាត។ យ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនោះមិនទាន់មានភាពសព្វគ្រប់ជ្រុងជ្រោយដើម្បីការពារទិន្នន័យផ្ទាល់របស់អ្នកប្រើប្រាស់ពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យមានប្រសិទ្ធភាពនៅឡើយទេ ដូច្នេះ កម្ពុជានៅតែត្រូវការក្របខ័ណ្ឌច្បាប់ដែលមានភាពទូលំទូលាយបន្ថែមទៀត សម្រាប់ការពារទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រាស់នៅក្នុងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## II. កិច្ចការពារទិន្នន័យផ្ទាល់ខ្លួនក្រោមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងចន្លោះប្រហោងនៃច្បាប់

ខណៈដែលអ្នកប្រើប្រាស់កាន់តែច្រើនអាចប្រើប្រាស់អ៊ីនធឺណិត និងពាក់ព័ន្ធសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពួកគេនឹងប្រឈមជាមួយបញ្ហាថ្មីៗបន្ថែមទៀត ខុសពីបញ្ហាដែលពួកគេធ្លាប់បានជួបកំឡុងពេលធ្វើពាណិជ្ជកម្មតាមបែបប្រពៃណី ឬពាណិជ្ជកម្មដោយមិនប្រើប្រព័ន្ធអ៊ីនធឺណិត។ ដូច្នេះហើយ ទើបតម្រូវឱ្យពួកគេសម្របខ្លួនអនុវត្តតាមក្របខ័ណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិនានា ចំពោះតម្រូវការដាក់លាក់នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ របាយការណ៍របស់វេទិកាសេដ្ឋកិច្ចពិភពលោកឆ្នាំ២០១៩ បង្ហាញថា “ឧបករណ៍និយត្តកម្មដែលមានបញ្ចូលនៅក្នុងច្បាប់ អាចបញ្ជាក់កាតព្វកិច្ចនៃព័ត៌មាន ការហាម

ប្រាមទាំងស្រុងនៃការបំភ័ន្ត និងការអនុវត្តខុសឆ្គង ការហាមឃាត់លក្ខខណ្ឌនៃកិច្ចសន្យាដែលមិនមានភាពយុត្តិធម៌តាមប្រភេទនៃកិច្ចសន្យានីមួយៗ និងចំណុចផ្សេងៗទៀត”។

ជាមួយនឹងនិន្នាការថ្មីនៃការធ្វើអាជីវកម្ម ក៏ដូចជាអនុលោមតាមការប្តេជ្ញាចិត្តរបស់កម្ពុជាក្រោមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្រសួងពាណិជ្ជកម្មបានចាប់ផ្តើមធ្វើសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាំងពីឆ្នាំ២០១២មកម្ល៉េះ។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ និងត្រូវបានអនុម័តដោយព្រឹទ្ធសភាលើទម្រង់និងគោលគំនិតច្បាប់ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ហើយ ត្រូវបានអនុម័តជាស្ថាពរនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមាន១២ជំពូក ៦៧មាត្រា និងឧបសម្ព័ន្ធចំនួន០១ ដែលអាចអនុវត្តបានសម្រាប់គ្រប់សកម្មភាពពាណិជ្ជកម្ម និងស៊ីវិល ការរក្សាទុកជាឯកសារ និងប្រតិបត្តិការនានាដែលធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិក។ ចំណុចសំខាន់ៗនៃច្បាប់រួមមានបទប្បញ្ញត្តិទាក់ទងនឹងសុពលភាព និងដំណើរការនៃទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក កំណត់ត្រាអេឡិចត្រូនិក និងសុវត្ថិភាពនៃហត្ថលេខាអេឡិចត្រូនិក សិទ្ធិនិងកាតព្វកិច្ចនៃភ្នាក់ងារផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងអន្តរការី កិច្ចការពារអ្នកប្រើប្រាស់ថ្នាលអេឡិចត្រូនិក ការប្រើប្រាស់សកម្មភាពអេឡិចត្រូនិចនិងប្រតិបត្តិការដោយរដ្ឋាភិបាលនិងស្ថាប័នរដ្ឋ ការទទួលស្គាល់ភស្តុតាងអេឡិចត្រូនិកនៅក្នុងនីតិវិធីរបស់តុលាការ ការផ្ទេរនិងទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងបទប្បញ្ញត្តិស្តីពីការផាកពិន័យ។

នៅក្នុងឯកសារស្តីពី “វប្បធម៌និងច្បាប់របស់កម្ពុជាស្តីពីឯកជនភាពនិងកិច្ចការពារទិន្នន័យ និងនាពេលអនាគត” សុធី បានសរសេរថា “មាត្រា៣២ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺជាជំហានដំបូងឆ្ពោះទៅរកការផ្តល់ការការពារសម្រាប់សិទ្ធិឯកជនរបស់ប្រជាជនកម្ពុជាចំពោះឯកជនភាពនិងទិន្នន័យរបស់ពួកគេ ទោះយ៉ាងណា ចំណុចមួយចំនួននៃច្បាប់នេះ មិនមានភាពច្បាស់លាស់និងមិនមានលក្ខណៈទូលំទូលាយទេ”។ យោងទៅតាម DLA Piper (២០២២) “ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានគ្របដណ្តប់បម្រាមនានាចំពោះសកម្មភាពឧក្រិដ្ឋកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលរួមមានការជ្រែកចូលប្រព័ន្ធអេឡិចត្រូនិកណាមួយក្នុងគោលបំណងចូលប្រើ ទាញយក ថតចម្លង ស្រង់ចេញ ធ្វើឱ្យលេចធ្លាយ លុបចោល ឬរក្សាទុកទិន្នន័យក្នុងគោលបំណងអាក្រក់ ឬដោយគ្មានការអនុញ្ញាត”។ ទាក់ទងទៅនឹងឯកជនភាព និងកិច្ចការពារទិន្នន័យ មាត្រា៣២ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានចែងថា “ជនណាដែលរក្សាទុកកំណត់ត្រាព័ត៌មានផ្ទាល់ខ្លួនលើថ្នាលអេឡិចត្រូនិកត្រូវធ្វើយ៉ាងណាធានាថា ព័ត៌មានទាំងនោះត្រូវបានការពារដោយភាពសមស្របនិងសុវត្ថិភាព ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ដើម្បីជៀសវាងការបាត់បង់ មានគេលួចចូលមើល លួចចូលប្រើប្រាស់ លួចកែប្រែ និងធ្វើឱ្យលេចធ្លាយ ឬបញ្ចេញព័ត៌មានទាំងនោះ ដោយគ្មានការអនុញ្ញាតពីសាមីខ្លួនដែលជាម្ចាស់ទិន្នន័យ”។ បន្ថែមលើមាត្រា៣២ មានការបំពេញបន្ថែមនៅក្រោមមាត្រា២២ “ដែលហាមឃាត់សកម្មភាពប្រើអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ កំណត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខកូដសម្ងាត់ ឬអត្តសញ្ញាណរបស់អ្នកដទៃក្នុងន័យមិនស្មោះត្រង់ ឬដោយមិនមានការអនុញ្ញាត សម្រាប់ប្រតិបត្តិការពាណិជ្ជកម្មឬមិនមែនពាណិជ្ជកម្មនៅក្នុងប្រព័ន្ធអេឡិចត្រូនិក”។

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់កម្ពុជា បានផ្តល់នូវតម្រូវការទូទៅលើដំណើរការ និងការរក្សាទុកទិន្នន័យ សម្រាប់អ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងអន្តរការី។ “អ្នកផ្តល់សេវាកម្មអេឡិចត្រូនិក” គឺជា “អ្នកដែលប្រើមធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញនិង/ឬសេវាកម្ម លើកលែងតែការផ្តល់សេវាជានារ៉ាប់រង” និង “អន្តរការី” ត្រូវបានកំណត់ថាជា “បុគ្គលដែលផ្តល់សេវាកម្មក្នុងការផ្ញើ, ការទទួល, ការបញ្ជូន ឬរក្សាទុកទាំងបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍, ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក ឬសេវាកម្មផ្សេងទៀតទាក់ទងនឹងទំនាក់ទំនងអេឡិចត្រូនិក រួមទាំងអ្នកដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក, អ្នកផ្តល់សេវាកម្មទូរគមនាគមន៍, អ្នកផ្តល់សេវាបណ្តាញ, អ្នកផ្តល់សេវាអ៊ីនធឺណិត, អ្នកផ្តល់សេវា

ស្រាវជ្រាវ, អ្នកផ្តល់សេវាទូទាត់តាមអ៊ីនធឺណិត, អ្នកផ្តល់សេវាដេញថ្លៃតាមអ៊ីនធឺណិត, អ្នកផ្តល់សេវាទីផ្សារអនឡាញ, និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមអ៊ីនធឺណិត។

ជាទូទៅ នៅក្រោមច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក អ្នកផ្តល់សេវាកម្មអេឡិចត្រូនិកត្រូវបានទាមទារឱ្យយល់ព្រមទទួលខុសត្រូវលើការរក្សាទុក ឬការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដទៃ។ លើសពីនេះ អ្នកផ្តល់សេវាដែលរក្សាទុកទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដទៃនៅក្នុងថ្នាលអេឡិចត្រូនិករបស់ខ្លួន ត្រូវតែអនុវត្តនីតិវិធីចាំបាច់ទាំងអស់ ដើម្បីធានាថាទិន្នន័យទាំងនោះត្រូវបានការពារដោយសុវត្ថិភាពទោះជានៅក្នុងកាលៈទេសៈសមស្របណាមួយក៏ដោយ។ យោងតាមលោក សុវ៉ាត "ទោះបីច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានបង្កើត សញ្ញាណនៃកិច្ចការពារទិន្នន័យនៅកម្ពុជាក៏ដោយ ក៏សញ្ញាណ នេះគ្របដណ្តប់តែលើ គោលការណ៍ការពារសុវត្ថិភាពទិន្នន័យ ដោយមិនគ្របដណ្តប់គោលការណ៍សំខាន់ៗជាច្រើនទៀត មានដូចជាគោលការណ៍នៃការបើកចំហរ ភាពងាយស្រួល ការចូលប្រើនិងកែប្រែ ការកំណត់ពីការប្រមូលព័ត៌មាន ការបញ្ជាក់គោលបំណង ការប្រើប្រាស់ដែនកំណត់ និងភាពត្រឹមត្រូវនៃទិន្នន័យ"។ លោក សុវ៉ាត ក៏បានបង្ហាញថា "ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនអាចគ្រប់គ្រងទិដ្ឋភាពលម្អិតជាច្រើនទៀតនៃច្បាប់ស្តីពីការការពារទិន្នន័យ ដូចជាវិសាលភាពនៃការការពារ កាតព្វកិច្ចនៃអ្នកគ្រប់គ្រងនិងអ្នកដំណើរការ សិទ្ធិនៃការរក្សាទិន្នន័យ ក៏ដូចជាការត្រួតពិនិត្យនិងការអនុវត្តច្បាប់"។

តាមទស្សនៈខាងលើ មានផលបច្ច័យមួយចំនួនជុំវិញកិច្ចការពារទិន្នន័យក្រោមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់កម្ពុជា។ ចំណុចទី១ កម្ពុជាមិនមានបទប្បញ្ញត្តិ ឬការគ្រប់គ្រងការអនុវត្តច្បាប់ដើម្បីត្រួតពិនិត្យ ដោះស្រាយ និងអនុវត្តបញ្ហាទាក់ទងនឹងការការពារទិន្នន័យផ្ទាល់ខ្លួននៅកម្ពុជា។ ខណៈមិនមានច្បាប់ជាក់លាក់ស្តីពីកិច្ចការពារទិន្នន័យ មានស្ថាប័នរដ្ឋចំនួន៣ដែលមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធកិច្ចការពារទិន្នន័យទាំងនោះ រួមមាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងពាណិជ្ជកម្ម និងក្រសួងមហាផ្ទៃ។ ចំណុចទី២ គឺមិនមានការតម្រូវឱ្យចុះបញ្ជីច្បាស់លាស់សម្រាប់ការការពារទិន្នន័យទេ។ ដូច្នេះ អ្នកផ្តល់សេវាកម្មអេឡិចត្រូនិក និងអន្តរការី ដែលមានបំណងរក្សាទុក ដំណើរការ និងផ្ទេរទិន្នន័យក្នុងកម្មវត្ថុនៃការប្រើប្រាស់ទិន្នន័យ ត្រូវតែធ្វើការចុះបញ្ជីជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម។ ចំណុចទី៣ គឺមិនមានបទប្បញ្ញត្តិជាក់លាក់ទាក់ទងនឹងការផ្ទេរទិន្នន័យនោះទេ។ យោងតាមស្ថាប័ន DLA Piper "ការដែលច្បាប់កម្ពុជាមិនបានហាមឃាត់ស្ថាប័នណាមួយក្នុងការផ្ទេរទិន្នន័យ គឺ បង្ហាញថា កាតព្វកិច្ចនៃការបង្ហាញ និងការជូនដំណឹងគឺអនុវត្តក្រោមក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ពាក់ព័ន្ធកិច្ចការពារទិន្នន័យ"។ ដូច្នេះទិន្នន័យផ្ទាល់ខ្លួនអាចត្រូវបានប្រមូលផ្តុំ ត្រូវបានប្រើ ឬត្រូវបានបង្ហាញសម្រាប់តែគោលបំណងណាមួយក្រោមការយល់ព្រមពីបុគ្គលនោះតែប៉ុណ្ណោះ ហើយការយល់ព្រមបែបនោះត្រូវតែបង្ហាញឬជូនដំណឹងពីកម្មវត្ថុនៃការប្រើប្រាស់ទិន្នន័យ។ នោះមានន័យថា មុនពេលធ្វើការប្រមូលទិន្នន័យ ប្រើប្រាស់ទិន្នន័យ ឬបង្ហាញទិន្នន័យរបស់បុគ្គលទៅតាមកម្មវត្ថុនៃការប្រើប្រាស់ទិន្នន័យ អ្នកផ្តល់សេវាកម្មឬអន្តរការីត្រូវតែជូនដំណឹង ឬបញ្ជាក់ពីចេតនា ឬគោលបំណងនៃកម្មវត្ថុក្នុងការប្រើប្រាស់ទិន្នន័យ ដែលនឹងដើរតួជាសកម្មភាពចម្បងក្នុងការស្វែងរកការយល់ព្រមពីបុគ្គលដែលទិន្នន័យផ្ទាល់ខ្លួនរបស់គេនឹងត្រូវបានគេប្រមូលទុក ត្រូវបានប្រើប្រាស់ ឬត្រូវបានបង្ហាញ។ ការធ្វើបែបនេះ អ្នកផ្តល់សេវាកម្ម ឬអន្តរការីអាចជ្រើសរើសទម្រង់សមស្របនៃការជូនដំណឹង ដើម្បីទទួលបានការយល់ព្រមពីកម្មវត្ថុនៃការប្រើប្រាស់ទិន្នន័យ ដូចជាការធ្វើកិច្ចសន្យាផ្លូវការ ឬតម្រូវការផ្សេងៗ ដើម្បីអនុវត្តសកម្មភាពជាក់លាក់មួយចំនួន ដូចជាការផ្តល់ការយល់ព្រមលើលិខិតអនុញ្ញាត ការចុះហត្ថលេខា ឬយល់ព្រមតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត។ ដូច្នេះទាក់ទងនឹងការផ្ទេរ ឬលាតត្រដាងទិន្នន័យផ្ទាល់ខ្លួន ត្រូវតែមានការជូនដំណឹងផងដែរ បើមិនដូច្នេះនឹងបង្កឱ្យមានភាពមិនត្រឹមត្រូវ។

## III.សេចក្តីសន្និដ្ឋាន

ខណៈដែលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាមានភាពរីកចម្រើន ជាមួយនឹងប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិតកាន់តែច្រើនឡើង ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ក៏ជួបនូវហានិភ័យខ្ពស់ ប្រឈមនឹងការរំលោភបំពានពីសំណាក់អាជីវកម្មមួយចំនួន រួមមានអ្នកប្រមូលនិងអ្នកដំណើរការទិន្នន័យជាដើម។ ដូច្នេះ វិធីសាស្ត្រច្បាស់លាស់និងទូលំទូលាយជុំវិញកិច្ចការពារទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាត្រូវតែពិចារណាឱ្យបានល្អិតល្អន់ពីការអនុវត្តល្អបំផុត និងវិធានការសមស្របលក្ខណៈអន្តរជាតិ។ ឧទាហរណ៍៖ បទប្បញ្ញត្តិការពារទិន្នន័យទូទៅ (GDPR) នៅអឺរ៉ុប ទោះយ៉ាងណាកម្ពុជាមិនគួរយកបទប្បញ្ញត្តិទាំងស្រុងនៃច្បាប់របស់ប្រទេសដទៃទៀតបញ្ចូលក្នុងច្បាប់របស់ខ្លួនឡើយ ដោយហេតុថាកាតព្វកិច្ចពិសេសៗដែលអាចអនុវត្តបាននៅក្នុងប្រទេសដទៃទៀតប្រហែលជាមិនសមស្របសម្រាប់បរិបទរបស់កម្ពុជាទេ មូលហេតុដោយសារតែកត្តាមួយចំនួន ដូចជាអក្ខរកម្មបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា បរិបទសង្គមនិងវប្បធម៌ និងកម្រិតនៃភាពរីកចម្រើននៃសេដ្ឋកិច្ច ជាដើម។ និយាយបែបផ្សេង ដើម្បីបង្កើតមូលដ្ឋានបទប្បញ្ញត្តិដ៏រឹងមាំ សម្រាប់ការពារទិន្នន័យផ្ទាល់ខ្លួននៅកម្ពុជា ច្បាប់ស្តីពីកិច្ចការពារទិន្នន័យផ្ទាល់ខ្លួនគួរត្រូវបានបង្កើតដើម្បីគ្រប់គ្រងបញ្ហាសំខាន់ៗ មានដូចជាវិសាលភាពនិងដែនកំណត់នៃការការពារគោលការណ៍ដែលទាក់ទងនឹងការការពារទិន្នន័យ សិទ្ធិរបស់កម្មវត្ថុនៃការប្រើប្រាស់ទិន្នន័យ កាតព្វកិច្ចរបស់អ្នកត្រួតពិនិត្យទិន្នន័យ និងអ្នកដំណើរការទិន្នន័យ និងវិធានការចាំបាច់ផ្សេងទៀតផងដែរ។

## "LEGAL REGIME ON PERSONAL DATA PROTECTION UNDER E-COMMERCE LAW IN CAMBODIA"

*By Mr. KEO Buntheng, Chief of Commercial Law Bureau,*
*Department of Legal Affairs, Ministry of Commerce*

### I. Introduction

Along with the growth in internet and social media users, e-commerce has developed dramatically in Cambodia. The quick development of e-commerce has gradually changed how people purchase goods and services. The prevalence of electronic transactions has been beneficial since they offer consumers and businesses convenience, comfort, efficiency, flexibility, and reduced costs. However, electronic transactions brings about issues, risks and uncertainties that harm consumers.

'The right to privacy' and other issues relating to the protection of personal data, are broadly guaranteed by the Constitution of the Kingdom of Cambodia and other laws.[1]Article 40 of the Constitution stipulates, "The rights to privacy of residence, and the confidentiality of correspondence by mail, telegram, fax, telex, and telephone, shall be guaranteed." Under this Article, the Constitution recognizes the right to privacy of the residence and secrecy of the communication, but it is not precise whether the right to privacy recognized under this Article is extended to data protection.

Currently, the latest development in personal data protection's legal framework in Cambodia is the enactment of E-Commerce Law, which sets out provisions for the protection of consumer's personal data in electronic communication. The protection of information to prevent its loss, access, use, modification, leak, or disclosure was briefly discussed in Article 32 of the Law on E-Commerce, along with the prohibitions against interfering with the electronic system, accessing, retrieving, copying, extracting, leaking, deleting, or otherwise altering data that is held, kept, or stored by any other person in bad faith, iniquity, or without authorization. However, the provisions are insufficient to effectively protect the personal data of consumers engaging in E-Commerce activities; therefore, Cambodia still needs a more comprehensive legal framework on personal data protection in E-Commerce.

### II. Personal Data Protection under the Law on E-Commerce and the Legal Gaps

As more consumers are getting access to the Internet and involving in e-commerce, there are also more new challenges for the consumers, which are different from the ones they encountered when conducting commercial activities traditionally or offline. Therefore, there is a need to adapt current frameworks of laws and regulations to certain requirements of e-commerce. According to World Economic Forum (2019), "regulatory instruments, embodied in legislation, can specify a duty of information, a total prohibition of misleading and aggressive practices, a prohibition of unfair contract terms in certain types of contracts and so on."[2]

With new business trends as well as to comply with Cambodia's commitments under the frameworks of World Trade Organization (WTO) and E-ASEAN Agreement, the Ministry of Commerce has started to work on the E-Commerce Draft Law since 2012. The draft law was then adopted by the National Assembly on October 08, 2019, approved by the Senate on its form and legal concept on 18 October 2019, and was promulgated November 02, 2019. The Law on E-Commerce consists of twelve chapters, sixty-seven articles, and one annex, which are applicable to all commercial and civil acts, documents, and transactions made through electronic system. Key features of the law include provisions relating to validity and process of

---

[1] See DLA Piper. (2022). Data Protection Laws of The World-Cambodia. Retrieved https://www.dlapiperdataprotection.com/system/modules/za.co.heliosdesign.dla.lotw.data_protection/functions/handbook.pdf?country-1=KH

[2] See World Economic Forum (2019). The Global Governance of Online Consumer Protection and E-commerce. Geneva: WEF Publication, p.6.

electronic communications; the electronic records and e-signatures' security; rights and obligations of e-commerce service providers and intermediaries; consumer protection on electronic platforms; the use of electronic acts and transactions by government and state institutions; recognition of e-evidence in court proceedings; electronic fund transfers and payments; and provisions on penalties.

In a paper on "Cambodia's Culture and Laws on Privacy and Data Protection, and the Future", Sothie (2021) wrote that "Article 32 of the E-Commerce Law is the first step towards providing protection for Cambodians' right to privacy and their data; however, the Law at some points is vague and not comprehensive."[3] According to DLA Piper (2022), "the E-Commerce Law makes a blanket prohibition on certain forms of cybercrime, including interference with any electronic system for the purpose of accessing, downloading, copying, extracting, leaking, deleting, or otherwise modifying any stored data in bad faith or without authorized permission."[4] With respect to data privacy and protection, Article 32 of this E-Commerce Law provides that "any persons storing electronic record of personal information shall use all means to ensure that the information is reasonably and safely protected in any circumstance to avoid loss, access, use, modification, and leak or disclose of such information without the authorization of the data holder." In addition to Article 32, there is a provision under Article 22 "prohibiting any use of the identity, record, electronic signature, electronic address, password, or other person's identification dishonestly or without permission for commercial or non-commercial transactions in the electronic system."

The Cambodian Law on E-commerce provides general requirements on data processing and storing for E-commerce service providers and intermediaries. "E-commerce service provider" means "a person who uses electronic means to supply goods and/or services except for insurance establishments"[5], and "Intermediary" is defined as "a person who provides services of sending, receiving, transmitting or storing, either on a temporary or permanent basis, electronic communications, or other services relating to electronic communications, including persons who represent the sender, receiver, transmitter, or the custodian; telecommunication service providers; network service providers; internet service providers; search engines providers; online payment service providers; online auction service providers; online marketplaces service providers; and internet commerce service provider."[6]

Generally, under the Law on E-Commerce, the E-commerce service providers are required to obtain expressed consent for any storage or usage of the other person's personal data and information.[7] Furthermore, the service provider holding or storing such personal data in electronic form must carry out all essential procedures to guarantee that the data is securely safeguarded in all reasonable circumstances.[8] According to Sovath (2021), "although the E-Commerce Law has introduced the notion of data protection in Cambodia, such introduction is very limited to the principle of data security safeguard and fails to include many other key principles such as the principles of openness, accessibility, access and correction, collection limitation, purpose specification, use limitation, and data integrity."[9] Sovath (2021) further states that "the E-Commerce Law fails to regulate many other aspects in detail of the data protection law such as the scope

---

[3] See Sothie, K. (2021). "2: Cambodia's Culture and Laws on Privacy and Data Protection, and the Future". in Konrad-Adenauer Stiftung. (2021). Law in the Digital Age: Protection of Consumer Rights. Phnom Penh: Konrad-Adenauer-Stiftung

[4] See *supra* note 1 at p.4.

[5] See Appendix No. 21 of the Law on E-Commerce, 2019

[6] See Appendix No. 25 of the Law on E-Commerce, 2019

[7] See ZICO Law. (2021). The State of E-Commerce in Cambodia. Retrieved https://www.zicolaw.com/resources/alerts/the-state-of-e-commerce-in-cambodia/

[8] See Article 32(1) of the Law on E-Commerce (2019)

[9] See Sovath, P. (2021). "3: Privacy and Data Protection in the Digital Age: A Holistic Approach to Privacy and Data Protection in Cambodia". In Konrad-Adenauer Stiftung. (2021). Law in the Digital Age: Protection of Consumer Rights. Phnom Penh: Konrad-Adenauer-Stiftung

of the protection, the obligation of controllers and processors, the rights of data subjects as well as oversight and enforcement."[10]

From the above perspectives, there are some implications on data protection under Cambodia's E-Commerce Law as follows. First of all, there are no regulatory or enforcement authorities to specifically oversee, handle, and implement matters relating to personal data protection in Cambodia. Since there is no specific law on data protection, there are three State bodies that have substantial powers over data protection matters, including the Ministry of Post and Telecommunications (MPTC), the Ministry of Commerce (MOC), and the Ministry of Interior (MOI). Second, there are no specific registration requirements for data protection. Therefore, it is only implied that the E-Commerce Service Providers and intermediaries, that want to store, process and transfer the data of the data subjects, must register with the Ministry of Post and Telecommunications (MPTC) and the Ministry of Commerce (MOC). Third, there are no specific provisions regarding data transfer. According to DLA Piper (2022), "While Cambodian law does not explicitly prohibit an organization from transferring data, it implies a disclosure/notification obligation under its existing legal framework for data protection."[11] Therefore, personal data can only be collected, used, or disclosed for purposes that the individual has given consent, and such purposes must be revealed or informed to data subjects. It means that, before collecting, using, or disclosing the personal data of data subjects, the service providers or intermediaries must inform or notify the intention or purposes to the data subjects, and it also acts as an essential action in seeking consent from the subjects whose personal data will be collected, used, or disclosed. In doing so, the service providers or intermediaries can choose appropriate forms of the notification to obtain the consent from the data subjects such as formal contracts or requirements to perform some specific actions such as clicking the consent button, signing, or reading through the terms and conditions. Therefore, regarding the transfer of personal data, the disclosure or transfer must be notified as well; otherwise, it will constitute the invalidity.

## III. Conclusion

As the E-Commerce in Cambodia is trendy with the existence of more online transactions, the consumers' personal data is also in higher risk in being violated by the businesses, data controllers and data processors. Therefore, a clearer and more comprehensive approach for personal data protection for E-Commerce's consumers in Cambodia must be adopted by taking into considerations international best practices and appropriate measures, i.e. the General Data Protection Regulations (GDPR) in Europe. However, Cambodia should not adopt full provisions of other countries' laws into its own law as particular obligations that are implementable in other countries might not be appropriate in Cambodia's context due to factors such as technological literacy, ICT infrastructures, social and cultural contexts, and level of economic developmec23vc23vhjvbihjknt. In other words, to establish strong and solid legal and regulatory grounds for personal data protection in Cambodia, the Law on Personal Data Protection is required in place to regulate significant matters such as scope and limitation of the protection, principles relating to the data protection, the data subject's rights, obligations of data controllers and data processors, and other necessary /measures.

## References


1. DLA Piper. (2022). DATA PROTECTION LAWS OF THE WORLD-Cambodia. Retrieved on July 20, 2022, from https://www.dlapiperdataprotection.com/system/modules/za.co.heliosdesign.dla.lotw.data.protection/functions/handbook.pdf?country-1=KH
2. Konrad-Adenauer Stiftung. (2021). *Law in the Digital Age: Protection of Consumer Rights* (K. Phallack & L. Chanbormey (eds.). Phnom Penh: Konrad-Adenauer-Stiftung
3. Sothie, K. (2021). "2: Cambodia's Culture and Laws on Privacy and Data Protection, and the Future". In


[10] ibid.

[11] See *supra* note 1 at p.5

Konrad-Adenauer Stiftung. (2021). Law in the Digital Age: Protection of Consumer Rights. Phnom Penh: Konrad-Adenauer-Stiftung

4. Sovath, P. (2021). "3: Privacy and Data Protection in the Digital Age: A Holistic Approach to Privacy and Data Protection in Cambodia". In Konrad-Adenauer Stiftung. (2021). Law in the Digital Age: Protection of Consumer Rights. Phnom Penh: Konrad-Adenauer-Stiftung
5. World Economic Forum (2019). The Global Governance of Online Consumer Protection and E-commerce. Geneva: WEF Publication
6. ZICO Law. (2021). The State of E-Commerce in Cambodia. Retrieved on July 25, 2022, from https://www.zicolaw.com/resources/alerts/the-state-of-e-commerce-in-cambodia/

# About the iTrade Bulletin

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world. This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.


**Honorable President**

H.E. Mr. PAN Sorasak

**Editorial Board**

- H.E. Mrs. CHAM Nimul (Chairwoman)
- H.E. Ms. SEREI Borapich
- Mr. HOR Iengchhay
- Mr. SOK Bunthorn

**Advisor**

- H.E. Mr. SIM Sokheng
- H.E. Mr. PENN Sovicheat
- H.E. Mr. SAMHENG Bora
- H.E. Dr. TAT Puthsodary
- H.E. Prof. Shandre Mugan THANGAVELU

**Teamwork**

- Mr. PAO Phireak
- Mr. CHINKET Tola
- Ms. YANGNY Chakriya
- Ms. CHEA Kunlak
- Mr. NY Atykunn
- Ms. PHAL Yita
- Mr. LY Rithy
- Mr. KHAM Chansopheak
- Mr. SE Sokunvathna
- Ms. VUTHY Sophanika


# Announcement

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

**Topics Covered:**

- International trade and logistics / trade laws;
- Digital economy / e-commerce;
- Economics and economic laws;
- Value added supply chains and logistics; and
- Facilitate the green business transition

**Categories:**

- Research articles
- Case reports
- Policy Briefs
- Commentaries or editorial


**Trade Training and Research Institute**

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

ttri.moc | www.ttri.info | @ttrimoccambodia